# រឿង មហាចោរនៅទល់ដែន

## ភាគទី៣ រាត្រីស្ងាត់ (ផ្នែកទី២)

- អូន! អូន! អូន!

យុវតីរឹតតែឱបគូជីវិតខ្លាំងទៅទៀត ដោយឥតឆ្លើយតបវិញឡើយ មានន័យបន្តវាចាទៅទៀតថា៖

- អូន! អូនកុំឲ្យខាតពេលយើង។
- ចាំ៎ះ!
- អូន! ម្តេចក៏ម្តងនេះ អូនហាក់ដូចជាញាប់ញ័រជាងសព្វថ្ងៃមួយដងម៉្លេះ? អូនមានរឿងអ្វី អូនកើតអ្វី?
- ចាំ៎ះ! ចាំ៎ះ! ខ្ញុំញ័រដោយត្រេកអរបានជួបនឹងបង ប្អូនអត់កើតអ្វីទេ ប្អូនសប្បាយ។ ទេ! ប្អូនមានទុក្ខ អ៊ូ! ទេ ប្អូនសប្បាយទេ។
- ប្អូនសប្បាយ?
- ចាំ៎ះ! ប្អូនសប្បាយ! ប្អូនសូមជម្រាបរឿងមួយដល់បងឲ្យបានជ្រាប។ រឿងប្អូនជាស្រីដូចស្រីឯទៀត។ រឿងប្អូនឥតប្លែកពីស្រីឯទៀតទេ។ ចាំ៎ះ! ចាំ៎ះ! រឿងប្អូនដូចជារឿងអ្នកឯទៀត... ។

មានន័យសើចដោយឃើញថា នាងនិយាយពុំទៅមុខសោះ។ បុរសអង្រួនស្មានាងថា៖

- នែ! បងស្តាប់បានហើយ! រឿងអ្វី?

នារីជំទើតចុងជើង ដើម្បីឲ្យមាត់របស់នាងទៅជិតត្រចៀកប្តីនាងបន្តិចទៅទៀត៖

- បង! បង!
- បាទ!
- ប្អូន! ... ឱ! ... ប្អូននិយាយមិនរួចទេ។ ប្អូន... ។

អត្ថបទដោយ៖ មាស សុភាព

មានទន្ទឹងដើមទ្រូង និយាយដាច់ៗនេះជាពន់ពេក តែបុរសឃើញថា កែវកម្សត់ប្រែកេទខុសពីធម្មតាខ្លាំងណាស់។ អ្នកឱបរឹតជីតារឹតតែខ្លាំងឡើង។ អ្នកយកម្រាមដៃអង្អែលសាច់នាងថ្នមៗ រួចពោលសម្ដីយ៉ាងទន់ភ្លន់ថា៖

- អូន! សូមនិយាយមក កុំឲ្យបងចាំស្ដាប់យូរពេក។ ប្អូនធ្លាប់កប់ប្រសព្វនឹងបង ជាយូរណាស់មកហើយ។ គួរណាស់ តែអូនស្ដាប់បងឲ្យជាក់។ អូនៗ សូមទុកចិត្តបងចុះ បងនឹងជួយអូន ទោះដល់ក្ដីមរណៈក៏បងហ៊ានដែរ។ ឱ! ក្នុងជាតិនេះ បងស្រឡាញ់អូនអស់ប៉ុណ្ណឹងហើយ គឺជាឥតមានរបស់អ្វីមកប្រៀបធៀបបានទេ។ សូមអូននិយាយមកចុះ បងចាំស្ដាប់។
- ចាំះ! ... ចាំះ! ... ហ៊ឺ! ប្អូននិយាយមិនបានទេ។ ចាំយប់ស្អែកទៀតចុះ។
- ទេ! បងចង់ដឹងតែយប់នេះឯង។
- ចាំះ! ហ៊ឺ! សូមចាំដល់យើងបែកគ្នាសិន។
- ទេ! បងចង់ដឹងតែឥឡូវនេះឯង។
- បង! បង!

នារីឱបបុរសយ៉ាងខ្លាំងជាថ្មីម្ដងទៀត រួចបន្តវាចាថា៖

- ចាំះ! បងៗ ប្អូនខ្មាសបងណាស់។
- អូនមិនស្រឡាញ់បងទេ?
- អូនស្រឡាញ់ៗជីវិតមួយ។
- ប្រាប់មក។
- ចាំះ! ប្អូនមាន... ។
- មានអី?
- ផ្ទៃពោះ។
- មានផ្ទៃ? អីអូនមានផ្ទៃពោះ?
- ចាំះ! ប្អូនជាមាតានៃបុត្ររបស់បងចំនួនពីរខែហើយ។

អត្ថបទដោយ៖ មាស សុភាព

បុរសចាប់មុខនាង ដៃទាំងពីរច្របាច់ដោយស្នេហា និងដោយរីករាយយ៉ាងខ្លាំង។ នារីបន្តកិច្ចសន្ទនាតទៅទៀតថា៖

- ចាំះ! ប្អូនមានផ្ទៃពោះ បន្តិចទៀត បុត្រមួយនឹងកើតឡើងមានរូបល្អដូចបង។ ក្នុងសាច់សរសៃឆ្អឹងរបស់កូននេះ ឈាមបង និងឈាមប្អូនហូរលាយគ្នា។ ឱ បង! កូននោះមានឬកពាដូចបង មានសម្តីដូចបង មានសន្តានចិត្តដូចបងមិនខាន។ បន្តិចទៀត ប្អូនបីបុត្រនោះនឹងដៃប្អូនហើយ។ ឱ! បន្តិចទៀតប្អូនបំបៅបុត្រនោះ ប្អូនចិញ្ចឹមបុត្រនោះ។ បង! បងធ្វើយ៉ាងណា? ឥឡូវនេះ? ដើម្បីកុំឲ្យអ្នកជិតផងតិះដៀលប្អូនជាស្រី! បងចោលប្អូនឬ?

ទឹកភ្នែកហូរសស្រាក់ពីភ្នែកនាងទេវី។ មានន័យរំជួលដួងចិត្ត អាណិតសង្សារកម្សត់។ អ្នកតបថា៖ មិនអីទេ យើងរៀបការគ្នាឆាប់ៗនេះ។

កញ្ញារីករាយយ៉ាងណា អស្ចារ្យនឹងពាក្យនេះ។ គឺជាពាក្យដែលនាងរង់ចាំប្តូរស្លាប់ ប្តូររស់។

- ចុះ ឪពុកបងថាម៉េច?
- ឪពុកជាឪពុក ប្រពន្ធជាប្រពន្ធ!

ទេវីទទួលពាក្យនេះដោយពេញចិត្តទៀត។ ស្ត្រីសើចទាំងទឹកភ្នែករមៀល ស្រក់តក់ៗ ធ្លាក់លើទ្រូងមានន្ទ ដែលមានចិត្តខ្លោចផ្សាឥតឧបមា។

បុរសពុំចង់ឲ្យនាងយំទេ ពុំចង់ឲ្យនាងកើតទុក្ខទេ អ្នកចង់ឲ្យសង្សារសប្បាយ។ អ្នកពន្យល់នាងថា៖ កុំយំអូន! គេយំតែកាលណាស្រុកខ្ញុំគេ។ បងមិនចោលអូនទេ បងប្តេជ្ញាថាទោះមានរឿងរ៉ាវឪពុកម្តាយ បងប្អូន ជំទាស់យ៉ាងណា ក៏បងយកអូនជាប្រពន្ធដែរ។ ចូរអូនកុំភ័យអី ព្រោះយើងនិយាយថា យើងសាងសុខដោយខ្លួនយើង។ យើងគ្មានគំនិត ពឹងផ្អែកផ្តេករកសុខលើចន្ទល់អ្នកណាទេ។ អូននិងបង បានគិតហើយ បានយល់ហើយ យើងស្រឡាញ់គ្នា។ គំនិត និងបំណងនេះ ជាទេពវត្ថុ ដែលគ្មានអ្វីមករំលាយបានឡើយ។

(សូមរង់ចាំតាមដានភាគបន្តនៅសប្តាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព